**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៣ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតអគ្គាធិការដ្ឋាន ចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១.-**

ត្រូវបានបង្កើត **អគ្គាធិការដ្ឋាន** ចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា ២.-**

ត្រូវបានផ្ទេរនាយកដ្ឋានអធិការកិច្ចភូមិបាលចេញពីអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រ និង អធិការដ្ឋាននៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មកចំណុះអគ្គាធិការដ្ឋាន។

## ជំពូកទី ២

## បេសកកម្ម ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ៣.-**

អគ្គាធិការដ្ឋាន មានបេសកកម្មជាសេនាធិការជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លើការងារ ÷

- ធ្វើអធិការកិច្ចជាប្រចាំទៅលើដំណើរការរដ្ឋបាល ការអនុវត្តច្បាប់ និងគោលការណ៍ណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយម្ម និងសំណង់ នៅគ្រប់អង្គភាពក្រោមឱវាទក្រសួងលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី ភូមិសាស្ត្រ និងការងារលំនៅឋាន
- ពិនិត្យសម្របសម្រួល និងដោះស្រាយវិវាទរដ្ឋបាលដែលពាក់ព័ន្ធនឹងអង្គភាព និងមន្ត្រី
- ត្រួតពិនិត្យពាក្យបណ្តឹងតវ៉ា ឬបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋ ឬសង្គមស៊ីវិល ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់មន្ត្រី និងការងារដែលទាក់ទងនឹងសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ធ្វើអធិការកិច្ច និងត្រួតពិនិត្យគុណភាពបច្ចេកទេសសុរិយោដីនិងការអនុវត្តនីតិវិធីចុះបញ្ជីដីធ្លី
- ធ្វើរបាយការណ៍ជាប្រចាំជូនរដ្ឋមន្ត្រីអំពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចរួច និងផ្តល់អនុសាសន៍កែលម្អការប្រព្រឹត្តទៅរបស់អង្គភាពនោះ និង
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី។

អគ្គាធិការដ្ឋាន ដឹកនាំដោយ អគ្គាធិការ ០១ រូប និងមានអគ្គាធិការរងមួយចំនួនតាមការចាំបាច់។

**មាត្រា ៤.-**

អគ្គាធិការដ្ឋាន មានអង្គភាពចំណុះ ចំនួន ០២ គឺ÷

១-នាយកដ្ឋានត្រួតពិនិត្យ និងទទួលពាក្យបណ្តឹង

២-នាយកដ្ឋានអធិការកិច្ចភូមិបាល

អង្គការលេខរបស់អគ្គាធិការដ្ឋាន ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

នាយកដ្ឋានត្រួតពិនិត្យ និងទទួលពាក្យបណ្តឹង មានតួនាទី និងភារកិច្ច ដូចតទៅ៖

- រៀបចំផែនការចុះធ្វើអធិការកិច្ចទូទៅលើកិច្ចដំណើរការរដ្ឋបាលគ្រប់អង្គភាពក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សំដៅពង្រឹងអភិបាលកិច្ចល្អ
- ត្រួតពិនិត្យបណ្តឹងតវ៉ា ឬបណ្តឹងបរិហារ របស់ប្រជាពលរដ្ឋ ឬសង្គមស៊ីវិល ពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់មន្ត្រី និងការងារដែលទាក់ទងនឹងសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ពិនិត្យសម្របសម្រួល និងដោះស្រាយវិវាទរដ្ឋបាលដែលពាក់ព័ន្ធនឹងមន្ត្រី
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចជូនអគ្គាធិការ
- រៀបចំ និងលើកសំណើផែនការថវិការបស់នាយកដ្ឋាន និង
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់អគ្គាធិការ។

**មាត្រា ៦.-**

នាយកដ្ឋានអធិការកិច្ចភូមិបាល មានតួនាទី និងភារកិច្ច ដូចតទៅ៖

- ធ្វើអធិការកិច្ច ត្រួតពិនិត្យគុណភាពបច្ចេកទេសសុរិយោដី និងការអនុវត្តនីតិវិធីចុះបញ្ជីដីធ្លី
- ផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់និងគោលការណ៍ណែនាំរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដល់មន្ត្រីរដ្ឋបាលដីធ្លី
- ត្រួតពិនិត្យការកាន់កាប់ឯកសារសុរិយោដី
- ពិនិត្យសម្របសម្រួល និងដោះស្រាយវិវាទពាក់ព័ន្ធការចេញប័ណ្ណកម្មសិទ្ធិដីធ្លី
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការចុះធ្វើអធិការកិច្ចជូនអគ្គាធិការ
- រៀបចំ និងលើកសំណើផែនការថវិការបស់នាយកដ្ឋាន និង
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់អគ្គាធិការ។

**មាត្រា ៧.-**

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាន ០១ រូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

**មាត្រា ៨.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីមួយៗនៃអគ្គាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.៧៧.អនក្រ.បក ចុះថ្ងៃទី.០៥..ខែឧសភា.ឆ្នាំ២០១៦**
**ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គាធិការដ្ឋាន**
**ចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

**អង្គការលេខរបស់អគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

